# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៤ សរណន

# សារាចរណែនាំ
## ស្តីពី
## ការចាត់តាំងខួបអនុស្សាវរីយ៍លើកទី ១១៨
## ទិវាពលកម្មអន្តរជាតិ ០១ ឧសភា ឆ្នាំ ២០០៤

ទិវាពលកម្មអន្តរជាតិ ១ឧសភា គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃចលនាកម្មករអន្តរជាតិ ដែលចាប់ផ្តើមឡើងនាឆ្នាំ ១៨៨៦ ក្នុងគោលបំណងធ្វើអោយប្រសើរនូវស្ថានភាពនៃលក្ខខណ្ឌការងារ និង ជីវភាពរស់នៅរបស់ប្រជាពលករ។ នៅកម្ពុជា ទិវាពលកម្មអន្តរជាតិ ០១ ឧសភា ត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំ តាំងពីក្រោយថ្ងៃ ០៧ មករា ១៩៧៩ ហើយមកដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលក៏បានកំណត់យកថ្ងៃ ០១ ឧសភា គឺជាថ្ងៃបុណ្យការងាររបស់ពលករកម្ពុជា និងជាថ្ងៃឈប់សំរាករបស់កម្មករ និយោជិត។ បណ្តាស្ថាប័នរដ្ឋ កម្មករ និយោជិតនៃរោងចក្រ សហគ្រាស ជាច្រើនបានរៀបចំទិវានេះ ក្រោមបរិយាកាសសប្បាយរីករាយ សាមគ្គីភាព។

ព្រះរាជាណាចក្រកម្ពុជា បាន និងកំពុងអនុវត្តលក្ខខណ្ឌការងារ ធានាសិទ្ធិ ផលប្រយោជន៍កម្មករនិយោជិតតាមច្បាប់ស្តីពីការងារ និងបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិខាងការងារចំនួន១២ ក្នុងនោះមានអនុសញ្ញាស្នូលចំនួន៧។ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសំរាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ ត្រូវបានបង្កើតក្នុងគោលបំណងធ្វើអោយលក្ខខណ្ឌការងារ និងជីវភាពរបស់កម្មករ និយោជិត កាន់តែប្រសើរឡើង។ ទន្ទឹមនឹងការពង្រឹងការអនុវត្តន៍ច្បាប់ដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា យើងបានបន្តអនុវត្តគំរោងឃ្លាំមើលលក្ខខណ្ឌការងារឯករាជ្យ ដែលចាត់ចែងដោយអង្គការអន្តរជាតិខាងការងារ (ILO)។ លក្ខខណ្ឌការងារនៅកម្ពុជាមានការអភិវឌ្ឍន៍ល្អ ជាពិសេសពុំមានការងារដោយបង្ខំ ភាពរើសអើង និងពលកម្មកុមារ គួរឱ្យកត់សំគាល់ឡើយ។ សិទ្ធិសហជីព សិទ្ធិកូដកម្ម ឡុកអៅ ត្រូវបានអនុវត្តយ៉ាងពេញលេញ។ គណៈកម្មការប្រឹក្សាការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាយន្តការត្រីភាគី ត្រូវបានរៀបចំអនុវត្តតួនាទីភារកិច្ចយ៉ាងសកម្ម តាមការកំណត់នៃច្បាប់ និងធានាបាននូវភាពជាដៃគូរ របស់គ្រប់ភាគីពាក់ព័ន្ធក្នុងវិស័យការងារ។

វិស័យការងារកម្ពុជា បាននិងកំពុងជាកំលាំងជំរុញថ្មីមួយនៃការប្រកួតប្រជែង និងពង្រីកទីផ្សារ នាំចេញផលិត

ផលទៅ អាមេរិក អឺរ៉ុប និងប្រទេសដទៃទៀត ដែលបានបង្កើតការងារថ្មីជាច្រើនកន្លែង ។

ដើម្បីអោយការប្រារព្ធទិវាពលកម្មអន្តរជាតិ ០១ ឧសភា ខួបលើកទី ១១៨ ប្រព្រឹត្តទៅបានល្អ រាជរដ្ឋាភិបាល សូមធ្វើការណែនាំដូចខាងក្រោមនេះ :

១-ក្រសួងពត៌មាន ម៉ាស៊ីនឃោសនារបស់រដ្ឋត្រូវផ្សព្វផ្សាយ អោយសង្គមជាតិទាំងមូល យល់ពីអត្ថន័យទិវាពលកម្មអន្តរជាតិ ០១ ឧសភា គឺជាសមិទ្ធិផលរបស់មនុស្សជាតិ ដែលបានបង្កើតនូវលក្ខខណ្ឌការងារជាស្តង់ដា សំរាប់ការអនុវត្តនីសព្វថ្ងៃនេះ ជាអាទិ៍ពាក្យស្លោក ៨ ម៉ោងធ្វើការ ៨ ម៉ោងសំរាក ៨ ម៉ោងរៀនសូត្រ ជាដើម ។

២-ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវណែនាំសហគ្រាស គ្រឹះស្ថានសហការគ្នារៀបចំទិវា ០១ ឧសភា តាមរូបភាពដូចជា :

-រៀបចំចាត់តាំងការជួបជុំសំណេះសំណាលតាមសហគ្រាស គ្រឹះស្ថាន ទទួលអំណរទិវា ០១ ឧសភា ។

-ចាត់តាំងការជួបជុំជប់លៀង កំសាន្តសប្បាយ ការដើរកំសាន្ត គ្រប់រូបភាពតាមលទ្ធភាពរៀងៗខ្លួន ដើម្បីបង្កបរិយាកាសសាមគ្គីភាព ភាតរភាព នៅតាមសហគ្រាស គ្រឹះស្ថាន ។

៣-ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អាជ្ញាធរខេត្ត-ក្រុង និងស្ថាប័ន ពាក់ព័ន្ធទាំងអស់ ត្រូវតែមានការណែនាំសមត្ថកិច្ចរបស់ខ្លួនក្នុងការថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងបង្កលក្ខណៈងាយស្រួលដល់សហគ្រាស គ្រឹះស្ថាន ដែលបោះទីតាំងក្នុងមូលដ្ឋានរបស់ខ្លួន ក្នុងឱកាសទិវាបុណ្យ ០១ ឧសភា ឆ្នាំ ២០០៤ នេះ ។

រាជរដ្ឋាភិបាលសូមអំពាវនាវដល់អង្គការវិជ្ជាជីវៈ សមាគម និងប្រជាពលរដ្ឋទាំងអស់ ចូលរួមអបអរទិវា ០១ ឧសភា ក្នុងក្តីសោមនស្សរីករាយ សាមគ្គីភាព ភាតរភាព ដើម្បីការអភិវឌ្ឍន៍នៃប្រទេសជាតិយើង ។

ទទួលបាននូវសារាចរណែនាំនេះ សូមឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងគ្រប់ខេត្ត ក្រុង រៀបចំចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធិភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន-ស្ថាប័ន និងខេត្ត-ក្រុង
"ដើម្បីសហការអនុវត្ត"
-ឯកសារ - កាលប្បវត្តិ